# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ១៤៣៥ គ.ជ.ប

## សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសសមាសភាព គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងសមាជិកលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គ.ជ.ប ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ចំនួន **១២៥រូប** និងសមាជិកលេខាធិការដ្ឋានគណៈកម្មការ រាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) ចំនួន **៥០រូប** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។ សម្រាប់រាជធានី ខេត្តនីមួយៗ សមាសភាព គធ.ខប មានចំនួន **០៥ រូប** និងសមាជិក លគធ.ខប មានចំនួន **០២រូប** ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | ចំនួន ០១ រូប |
| ២- អនុប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | ចំនួន ០១ រូប |
| ៣- សមាជិក គធ.ខប ទទួលបន្ទុកផ្នែករដ្ឋបាល | ចំនួន ០១ រូប |
| ៤- សមាជិក គធ.ខប ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ | ចំនួន ០១ រូប |
| ៥- សមាជិក គធ.ខប ទទួលបន្ទុកផ្នែកបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត និងព័ត៌មាន និងទំនាក់ទំនងសាធារណៈ | ចំនួន ០១ រូប |
| ៦- សមាជិក លគធ.ខប ទទួលបន្ទុកផ្នែកប្រតិបត្តិការ និងបញ្ជីបោះឆ្នោត | ចំនួន ០១ រូប |
| ៧- សមាជិក លគធ.ខប ទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត | ចំនួន ០១ រូប |

បេក្ខជនដែលមានបំណងដាក់ពាក្យសុំប្រឡងចូលបម្រើការងារតាមមុខតំណែងខាងលើ សូមអញ្ជើញទៅមើលសេចក្តីជូនដំណឹង ស្តីពីលក្ខខណ្ឌនៃការជ្រើសរើសសមាសភាព គធ.ខប និងសមាជិក លគធ.ខប ការចែកពាក្យ និងការទទួលពាក្យសុំប្រឡងចូលបម្រើការងារ ដែលនឹងបិទផ្សាយនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត និងទីកន្លែងសាធារណៈក្នុងរាជធានី ខេត្ត ។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងចែកជូនដោយឥតគិតថ្លៃនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ។

សញ្ញាប័ត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន ។
- ការចាប់ផ្តើមចែក និងទទួលពាក្យនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ (វេលាម៉ោង៧:០០ព្រឹក)
- ការឈប់ទទួលពាក្យនៅ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ (វេលាម៉ោង១៧:៣០ល្ងាច) ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៧

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ស៊ិក ប៊ុនហុក

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខៈ ១៤៣៩ គ.ជ.ប

# សេចក្តីជូនដំណឹង

## ស្តីពី

## លក្ខខណ្ឌនៃការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងសមាជិកលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គ.ជ.ប ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ចំនួន **១២៥រូប** និងសមាជិកលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) ចំនួន **៥០រូប** ជាបគ្គលិកជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។ សម្រាប់រាជធានី ខេត្តនីមួយៗ សមាសភាព គធ.ខប មានចំនួន **០៥ រូប** និងសមាជិក លគធ.ខប មានចំនួន **០២រូប** ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | ចំនួន ០១ រូប |
| ២- អនុប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | ចំនួន ០១ រូប |
| ៣- សមាជិក គធ.ខប ទទួលបន្ទុកផ្នែករដ្ឋបាល | ចំនួន ០១ រូប |
| ៤- សមាជិក គធ.ខប ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ | ចំនួន ០១ រូប |
| ៥- សមាជិក គធ.ខប ទទួលបន្ទុកផ្នែកបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត និងព័ត៌មាន និងទំនាក់ទំនងសាធារណៈ | ចំនួន ០១ រូប |
| ៦- សមាជិក លគធ.ខប ទទួលបន្ទុកផ្នែកប្រតិបត្តិការ និងបញ្ជីបោះឆ្នោត | ចំនួន ០១ រូប |
| ៧- សមាជិក លគធ.ខប ទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត | ចំនួន ០១ រូប |

I- **លក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើស ៖**

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុចាប់ពី ២៥ឆ្នាំឡើងទៅ គិតដល់ថ្ងៃតែងតាំង
- មានសិទ្ធិបោះឆ្នោត នៅក្នុងរាជធានី ខេត្ត

- មានសញ្ញាប័ត្រ ឬបទពិសោធន៍ក្នុងការរៀបចំចាត់ចែងការងារបោះឆ្នោត
- មានបទពិសោធន៍ការងារតាមមុខតំណែង
- មានសុខភាពល្អ
- មានចរិតស្មោះត្រង់ និងសុចរិតទៀងត្រង់ គោរពច្បាប់
- មិនមែនជាសមាជិកកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ
- មិនមែនជាមេភូមិ ឬជំនួយការមេភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវលាលែងពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច
- បេក្ខនារី ឬ បេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនដែលមានពិការភាព ដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែង ត្រូវបានលើកទឹកចិត្ត ។

II- **លក្ខខណ្ឌបច្ចេកទេសដែលទាមទារដើម្បីបំពេញការងារជាក់លាក់មួយចំនួនដូចជា ៖**

- មានចំណេះដឹងទាក់ទងជាមួយមុខតំណែង
- សម្រាប់តួនាទីមួយចំនួន ទាមទារឱ្យមានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- មានលទ្ធភាពធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ។

III- **លក្ខខណ្ឌដោយឡែក ÷**

១- ប្រធាន-អនុប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញាប័ត្រ ឬបទពិសោធន៍ក្នុងការរៀបចំចាត់ចែងការងារបោះឆ្នោត យ៉ាងតិច ៥ដង ឬ ការងារត្រូវនឹងការងារគ្រប់គ្រងយ៉ាងតិច ០៥ឆ្នាំ ។

២- សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល បេក្ខជនត្រូវមានសញ្ញាប័ត្រ បរិញ្ញាប័ត្ររង ឬបទពិសោធន៍ក្នុងការងារគ្រប់គ្រង និងចាត់ចែងការងារបោះឆ្នោតយ៉ាងតិច ៣ដង ឬបទពិសោធន៍ខាងការងាររដ្ឋបាលយ៉ាងតិច០៣ឆ្នាំ។

៣- សមាជិកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ បេក្ខជនត្រូវមានសញ្ញាប័ត្រ បរិញ្ញាប័ត្ររង ឬបទពិសោធន៍ក្នុងការចាត់ចែងការងារហិរញ្ញវត្ថុបោះឆ្នោត យ៉ាងតិច ៣ដង ឬបទពិសោធន៍ខាងការងារហិរញ្ញវត្ថុយ៉ាងតិច ០៣ឆ្នាំ។

៤- សមាជិកទទួលបន្ទុកផ្នែកបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត និងព័ត៌មាន និងទំនាក់ទំនងសាធារណៈ បេក្ខជនត្រូវមានសញ្ញាប័ត្រ បរិញ្ញាប័ត្ររង ឬបទពិសោធន៍ក្នុងការងារគ្រប់គ្រង និងចាត់ចែងការងារបោះឆ្នោត យ៉ាងតិច ៣ដង ឬបទពិសោធន៍ខាងការងារបណ្តុះបណ្តាលអប់រំ យ៉ាងតិច ០៣ឆ្នាំ ។

៥- សមាជិក លគធ.ខប ទទួលបន្ទុកផ្នែកប្រតិបត្តិការ និងបញ្ជីបោះឆ្នោត បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញាប័ត្ររង ឬបទពិសោធន៍ចាត់ចែងការងារបោះឆ្នោត យ៉ាងតិច ៣ដង ឬបទពិសោធន៍ខាងការងារក្នុងការចាត់ចែងប្រតិបត្តិការជំទូលាយ យ៉ាងតិច ០៣ឆ្នាំ ។

៦- សមាជិក លគធ.ខប ទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត បេក្ខជនត្រូវមានសញ្ញាប័ត្រ បរិញ្ញាប័ត្ររង ឬបទពិសោធន៍ក្នុងការងារគ្រប់គ្រង និងចាត់ចែងការងារបោះឆ្នោត យ៉ាងតិច៣ដង ឬបទពិសោធន៍ខាងការងារច្បាប់យ៉ាងតិច ០៣ឆ្នាំ ។

## IV- **ភារកិច្ច និងការទទួលខុសត្រូវនៃ គធ.ខប ÷**

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតមានតួនាទី ភារកិច្ច ៖

១- អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា នីតិវិធីនៃការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបានអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

២- អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យ ។

ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗរបស់ គធ.ខប មានដូចខាងក្រោម ៖

- គោរព និងអនុវត្តបទបញ្ជា និងនីតិវិធី និងគោលការណ៍ណែនាំរបស់ គ.ជ.ប
- អនុវត្តផែនការមេ និងប្រតិទិននៃការបោះឆ្នោត
- គ្រប់គ្រងថវិការបស់ គធ.ខប អនុលោមតាមបទបញ្ជា និងនីតិវិធី និងសេចក្តីណែនាំនានាពី គ.ជ.ប
- ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌តាមរយៈការបោះឆ្នោតដោយសម្ងាត់
- ការពារ និងធានាឱ្យបាននូវឯករាជភាព និងអព្យាក្រឹតភាពរបស់ គធ.ខប
- ត្រួតពិនិត្យដំណើរការរៀបចំការបោះឆ្នោតក្នុងរាជធានី ខេត្ត
- បូកសរុប ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានីខេត្ត និងប្រគល់កំណត់ហេតុទៅ គ.ជ.ប
- បណ្តុះបណ្តាលបុគ្គលិក សមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ទំនាក់ទំនងសហការជាមួយគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលក្នុងរាជធានី ខេត្តលើការងារអប់រំអ្នកបោះឆ្នោត និងការងារពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌
- ទំនាក់ទំនងសហការជាមួយអាជ្ញាធរគ្រប់ថ្នាក់ក្នុងរាជធានី ខេត្តដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សុវត្ថិភាព និងដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌
- អនុវត្តការដាក់ ការទទួល និងការដោះស្រាយបណ្តឹង និងវិវាទកម្មក្នុងសមត្ថកិច្ចរបស់ខ្លួន
- ក្តាប់សភាពការណ៍ព័ត៌មានជុំវិញការរៀបចំការបោះឆ្នោត ដើម្បីធ្វើការបំភ្លឺបកស្រាយ ឬដោះស្រាយ និងរាយការណ៍ទៅ គ.ជ.ប ឱ្យបានទាន់ពេលវេលា ។

## V- **រយៈពេលបម្រើការងារ**

ចាប់ផ្តើមចូលបម្រើការងារពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៨ ។

## VI- **ប្រាក់កម្រៃ**

| | | |
|---|---|---|
| - ប្រធាន គធ.ខប | ប្រាក់កម្រៃក្នុងមួយខែទទួលបាន | ៦.៤១៦.000 រៀល |
| - អនុប្រធាន គធ.ខប | ប្រាក់កម្រៃក្នុងមួយខែទទួលបាន | ៥.១៧៦.000 រៀល |
| - សមាជិក គធ.ខប | ប្រាក់កម្រៃក្នុងមួយខែទទួលបាន | ៣.៨៤0.000 រៀល |
| - សមាជិក លគធ.ខប | ប្រាក់កម្រៃក្នុងមួយខែទទួលបាន | ២.៥៦0.000 រៀល |

## VII- **ទំនាក់ទំនងព័ត៌មាន**

អ្នកដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទាក់ទងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការ នៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត ដែល គ.ជ.ប បានកំណត់ សម្រាប់ធ្វើជាកន្លែងចែកពាក្យ ទទួលពាក្យ ។

ពាក្យសុំប្រឡងចូលបម្រើការងារ នឹងមានចែកជូនដោយឥតគិតថ្លៃ ។

VIII - **វិញ្ញាសាប្រឡង**

- សំណួរសរសេរ ទាក់ទងនឹងមុខតំណែងមាន ៤សំណួរ
- សំណួរពហុជ្រើសរើស (QCM) ទាក់ទងនឹងមុខតំណែងចំនួន ៥សំណួរ
- សម្ភាសន៍ ចំណេះដឹងទូទៅទាក់ទងនឹងការងារបោះឆ្នោត ។

IX - **កាលបរិច្ឆេទនៃការទទួលពាក្យ និងការប្រឡងសរសេរ សំណួរពហុជ្រើសរើស** (QCM) **និងសម្ភាសន៍**

- ការចែកពាក្យ និងការទទួលពាក្យ : ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ( វេលាម៉ោង ៧:០០ ព្រឹក )
- ការឈប់ទទួលពាក្យ : ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ( វេលាម៉ោង ១៧:៣០ នាទីល្ងាច )
- កាលបរិច្ឆេទបិទផ្សាយបញ្ជីឈ្មោះប្រឡងសរសេរ-QCM និងសម្ភាសន៍ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧ និងកាលបរិច្ឆេទនៃការប្រឡងនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៧ សម្រាប់រាជធានី ខេត្ត ចំនួន ១៣ មាន ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តក្រចេះ រាជធានីភ្នំពេញ ខេត្តស្ទឹងត្រែង ។
- កាលបរិច្ឆេទបិទផ្សាយបញ្ជីឈ្មោះប្រឡងសរសេរ សំណួរពហុជ្រើសរើស (QCM) និងសម្ភាសន៍ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ និងកាលបរិច្ឆេទនៃការប្រឡងនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ សម្រាប់ខេត្តចំនួន ១២ មាន ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង ខេត្តកែប ខេត្តប៉ៃលិន ខេត្តសៀមរាប ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តព្រះវិហារ ខេត្តបាត់ដំបង ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ។

X- **ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

អនុគណៈកម្មការរៀបចំការប្រឡងតាមរាជធានី ខេត្ត ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជនដោយត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនណាដែលមានលក្ខខណ្ឌល្អជាងគេ មកប្រឡងសរសេរ សំណួរពហុជ្រើសរើស(QCM) និងសម្ភាសន៍។

សំណុំលិខិតរបស់បេក្ខជនមិនត្រូវបានប្រគល់ជូនវិញទេ ។

XI- **លទ្ធផលនៃការប្រឡងសរសេរ ពហុជ្រើសរើស** (QCM) **និងសម្ភាសន៍**

លទ្ធផលនៃការប្រឡងសរសេរ ពហុជ្រើសរើស(QCM) និងសម្ភាសន៍ នឹងបិទផ្សាយ នៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត និងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ គ.ជ.ប ។

**<u>បញ្ជាក់បន្ថែម</u>** :

- សញ្ញាប័ត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮ យ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ដែលនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- មាត្រា២៤ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា ... មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវរក្សាបៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ នៅអង្គភាពដើមរបស់ខ្លួនដដែល ។
- សហព័ទ្ធ ឬញាតិពន្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី៣ មិនត្រូវបានជ្រើសរើសឱ្យបំពេញការងារនៅក្នុងគណៈកម្មការតែមួយ ។/.

*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧*

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ១៤៣៦ គ.ជ.ប

## ជម្រាបមក

**លោក លោកស្រីប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត**

**កម្មវត្ថុ ៖** សេចក្តីណែនាំអំពីការបិទផ្សាយសេចក្តីជូនដំណឹងនៃការប្រឡងជ្រើសរើសសមាសភាព គធ.ឃប និងសមាជិក លគធ.ឃប សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

**យោង ៖** - ប្រតិទិនលេខ ១៤៣៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ស្តីពីការជ្រើសរើស ការតែងតាំង និងការបណ្តុះបណ្តាលមន្ត្រី បុគ្គលិក សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

- សេចក្តីជូនដំណឹងលេខ ១៤៣៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមកលោក លោកស្រីប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោតថា គណៈកម្មាធិការជាតិរៀបចំកាបោះឆ្នោត (គ.ជ.ប) ត្រូវការជ្រើសរើសសមាសភាព គធ.ឃប ចំនួន **១២៥នាក់** និងសមាជិក លគធ.ឃប ចំនួន **៥០នាក់** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ក្នុងនោះមួយរាជធានី ខេត្ត សមាសភាព គធ.ឃប ចំនួន **០៥នាក់** និងសមាជិក លគធ.ឃប ចំនួន **០២នាក់** ។ ក្នុងការប្រឡងសរសេរ ពហុជ្រើសរើស(QCM) និងសម្ភាសន៍ សមាសភាព គធ.ឃប និងសមាជិក លគធ.ឃប នាពេលខាងមុខនេះ គ.ជ.ប តម្រូវឱ្យលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត បិទផ្សាយសេចក្តីជូនដំណឹងជ្រើសរើសនៅ លធ.ឃប តាមទីប្រជុំជន ក្រុង ស្រុក ខណ្ឌ និងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយក្នុងរាជធានី ខេត្ត ប្រសិនបើអាចធ្វើបាន ដូចមានជូនភ្ជាប់មកជាមួយ ចាប់ពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ (វេលាម៉ោង ៧:០០ព្រឹក) ដល់ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៧ (វេលាម៉ោង ១៧:៣០នាទីល្ងាច) ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធាន លធ.ឃប ទាំងអស់ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព ។

សូមលោក លោកស្រី ទទួលនូវការរាប់អានពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១៧

**ជ.គណៈកម្មាធិការជាតរៀបចំការបោះឆ្នោត**

**ប្រធាន**

សុិក ប៊ុនហុក